# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានិងនៃការត្រាស់ហៅជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង
# ភ្នំពេញថ្មី ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩
## អធិដ្ឋានដើម្បីស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ កូឡូស ១,៩-១៤**

ព្រះអង្គបានរំដោះយើងឲ្យរួចផុតពីអំណាចនៃសេចក្ដីងងឹត ហើយចម្លងយើងចូលទៅក្នុងព្រះរាជ្យនៃព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។ កូឡូ ១,១៣

**ដំណឹងល្អ៖ លូកា ៥,១-១១**

ព្រះយេស៊ូមានព្រះបន្ទូលទៅលោកស៊ីម៉ូនថា៖ «កុំខ្លាចអី! ពីពេលនេះទៅមុខ អ្នកនឹងនេសាទមនុស្សវិញ»។ លក ៥,១០

បងប្អូនជាទីស្រឡាញ់!

នៅក្នុងអត្ថបទទី១ យើងបានស្ដាប់ "**យើងចេះតែអធិដ្ឋាននិងទូលអង្វរព្រះជាម្ចាស់ ឲ្យបងប្អូនឥតឈប់ឈរឡើយ ដើម្បីឲ្យបងប្អូនស្គាល់ព្រះហឫទ័យរបស់ព្រះអង្គយ៉ាងច្បាស់ ដោយមានគ្រប់ប្រាជ្ញានិងតំរិះដែលមកពីព្រះវិញ្ញាណ**"។ លោក ប៉ូល អធិដ្ឋានដើម្បីឲ្យបងប្អូនស្គាល់ព្រះហឫទ័យរបស់ព្រះអង្គយ៉ាងច្បាស់ នេះជាតួនាទីរបស់ព្រះសហគមន៍ជាពិសេសលោកឪពុក បងប្រុសបងស្រីនិងក្រុមគ្រួសារព្រះសហគមន៍ទូលំទូលាយ ដើម្បីអធិដ្ឋានយ៉ាងច្បាស់ឲ្យយុវជនដែលជាប្អូនរបស់យើងស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងដើម្បីឲ្យយើងស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរ។ លោក ប៉ូល ណែនាំឲ្យយើងចូលនៅក្នុងអ្វីដែលសំខានបំផុតនៅក្នុងតួនាទីរបស់យើងណែនាំឲ្យយើងអធិដ្ឋាន ដើម្បីស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់។

សន្ត លូវីស សន្តី ហ្សេលី អ្នកម្ដាយ តេរេសា សន្តី តេរេសា នៃព្រះកុមារយេស៊ូ អស់មួយជីវិតរបស់ពួកគាត់ បានយកចិត្តទុកដាក់អធិដ្ឋានដើម្បីស្គាល់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ពីមួយថ្ងៃទៅមួយថ្ងៃចូលនៅក្នុងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ដូច្នេះ សម្រាប់យើងដែលជាយុវជនយុវនារី ដែលចាប់ផ្ដើមគិតអំពីអនាគតផ្ទាល់ខ្លួន ជាឱកាសមួយដើម្បីចូលនៅក្នុងជីវិតរបស់អ្នកម្ដាយតេរេសាផង សន្ត លូវីស និងសន្តី ហ្សេលី សន្ត សិលា ផង ដើម្បីមើលដំណើរដែលសន្តសន្តីទាំងនេះ បានធ្វើជាមួយព្រះជាម្ចាសនៅក្នុងជីវិតរបស់ពួកគាត់។ នៅក្នុងជីវិតរបស់គេដែលជាមនុស្សសាមញ្ញធម្មតាដូចយើង យើងមិនដឹងទេនៅក្នុងចំណោមយុវជនយុវនារីនៅទីនេះនៅថ្ងៃស្អែកអាចមានម្នាក់មានការត្រាស់ហៅដូចសន្ត សិលា ឬដូចអ្នកម្ដាយតេរេសា ឬដូចសន្ត លូវីស និងសន្តី ហ្សេលី។ **តើព្រះជាម្ចាស់បានធ្វើអ្វីខ្លះជាមួយខ្ញុំ? តើព្រះជាម្ចាស់បានណែនាំខ្ញុំ**

**របៀបណា ដើម្បីចូលនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់?** អ្វីដែលជាសំខាន់ទាំងសន្ត សិលា ទាំងអ្នកម្ដាយតេរេសា ទាំងសន្ត លូវីស ទាំងសន្តី ហ្សេលី ពួកគេបានស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ តាមរបៀបមួយដែលគេបានជួបជាមួយព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំរបស់គេ។ ការជួបជាមួយព្រះជាម្ចាស់ ណែនាំឲ្យជីវិតរបស់គេទៅជាជីវិតថ្មីតែម្ដង អ្វីៗទាំងអស់ប្រែប្រួលនៅក្នុងជីវិតផ្ទាល់ខ្លួន។

សន្ត សិលា ការងាររបស់គាត់គឺនេសាទត្រី ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃគាត់ជិះទូកជាមួយអ្នកនេសាទត្រីដូចគ្នាដើម្បីចាប់ត្រី។ គាត់ធ្វើការងាររបស់គាត់ មានថ្ងៃពិសេសមួយដោយសារព្រះយេស៊ូទៅដែរ គាត់អត់ទាន់ស្គាល់ព្រះយេស៊ូប៉ុន្មានទេ ធ្លាប់តែឃើញព្រះយេស៊ូទៅនិយាយអំពីព្រះជាម្ចាស់ ព្រះយេស៊ូចាប់ផ្ដើមប្រកាសអំពីដំណឹងល្អ។ នៅពេលនោះព្រះយេស៊ូមានព្រះបន្ទូលថា "**ចូរបង្ហួសទូកទៅទឹកជ្រៅ រួចនាំគ្នាទម្លាក់អួនចុះ**" នៅពេលនោះគេឆ្ងល់ដោយសារបានត្រីយ៉ាងច្រើន មានអ្វីដែលកំពុងប្រែប្រួលនៅក្នុងជីវិតរបស់គាត់។

អ្នកម្ដាយតេរេសា គាត់ជាបងស្រីម្នាក់នៅក្នុងក្រុមគ្រួសារឡូរិច គាត់ជាសាសនទូតដែលចេញពីប្រទេសរបស់គាត់ ដើម្បីទៅដល់ប្រទេសឥណ្ឌាចូលនៅក្នុងក្រុមគ្រួសាររបស់គាត់។ គាត់ជាគ្រូបង្រៀនភូមិវិទ្យាជាមួយសិស្សសាលាធម្មតា នៅថ្ងៃ០៥ ខែកញ្ញា គាត់កំពុងធ្វើដំណើរចេញសាលារៀនដែលគាត់បង្រៀន តាមផ្លូវគាត់ឃើញមនុស្សម្នាក់ដែលកំពុងស្លាប់ នៅឥណ្ឌាតាមផ្លូវមានមនុស្សស្លាប់ច្រើននៅសម័យនោះ ខ្វះមន្ទីរពេទ្យ ខ្វះលុយ...។ អ្នកម្ដាយតេរេសាមើលឃើញអ្នកស្លាប់នោះ ហើយគាត់បន្តធ្វើដំណើរតែប៉ុន្មានម៉ែត្រ គាត់នឹកឃើញព្រះយេស៊ូលីឈើឆ្កាង នឹកឃើញព្រះយេស៊ូដែលកំពុងស្រេកទឹកនៅលើឈើឆ្កាង។ នៅពេលនោះរូបភាពមនុស្សដែលកំពុងស្លាប់នៅតាមផ្លូវ និងព្រះយេស៊ូដែលកំពុងស្រេកនៅលើឈើឆ្កាងចូលគ្នា ហើយគាត់យល់ថាអ្នកដែលកំពុងស្លាប់លើផ្លូវនេះ គឺព្រះយេស៊ូដែលកំពុងស្រេកទឹក។ នៅពេលនោះ គាត់បានជួបជាមួយព្រះយេស៊ូនៅក្នុងរបៀបថ្មីនៃជីវិតរបស់គាត់។

សន្ត លូវីស និងសន្តី ហ្សេលី ទាំងពីរនាក់គេមានគម្រោងការណ៍ហើយម្នាក់ទៅជាបូជាចារ្យម្នាក់ទៀតទៅជាបងស្រី តែធ្វើមិនបាន។ ដូច្នេះ គេចេញពីក្រុមបុព្វជិតបុព្វជិតានិងគេចាប់ផ្ដើមជីវិតធម្មតារបស់គេ មានថ្ងៃមួយព្រះជាម្ចាស់មានគម្រោងការណ៍ណែនាំឲ្យគេជួបគ្នានៅស្ពានមួយពេលពីរនាក់ជួបគ្នាគេយល់ថាយើងត្រូវតែធ្វើជាប្ដីប្រពន្ធ។ ពីមុនគេមិនស្គាល់គ្នា ប៉ុន្តែពេលគេចាប់ផ្ដើមនិយាយទៅគ្នាទៅវិញទៅមក ថាពីមុនខ្ញុំចង់ក្លាយជាបូជាចារ្យ ខ្ញុំចង់ធ្វើជាបងស្រី ប៉ុន្តែឥឡូវនេះព្រះជាម្ចាស់មានគម្រោងការណ៍ថ្មីសម្រាប់យើងទាំងពីរនាក់ គឺឲ្យយើងទៅជាប្ដីប្រពន្ធ

ឲ្យយើងបង្កើតគ្រួសារចាប់ពីពេលនេះតទៅ។ នៅពេលនោះគេបានជួបជាមួយព្រះយេស៊ូវបៀប ពិសេស ប៉ុន្តែនៅក្នុងជីវិតសាមញ្ញរបស់ពួកគេ ជីវិតថ្មីចាប់ផ្តើមហើយ។

ព្រះយេស៊ូមានព្រះបន្ទូលទៅលោកសិលាយ៉ាងច្បាស់ថា "**កុំខ្លាចអ្វី! ពីពេលនេះទៅមុខអ្នកនឹងនេសាទមនុស្សវិញ**" គាត់លែងជាអ្នកនេសាទត្រីគាត់មានតួនាទីថ្មី ការងារថ្មី ជីវិតថ្មី ដើរជាមួយព្រះយេស៊ូ ដើម្បីប្រមូលមនុស្សឲ្យគេស្គាល់ព្រះយេស៊ូ។ ម្តាយតេរេសា ក៏ដូចគ្នាដែរគាត់សុំចេញពីក្រុមបងស្រីរបស់គាត់ ដើម្បីចាប់ផ្តើមជីវិតថ្មី ដោយប្រមូលអ្នកក្រីក្រដែលមាននៅតាមផ្លូវ ប្រមូលអ្នកជំងឺដែលមាននៅតាមផ្លូវ និងចាប់ផ្តើមថែរក្សាគេឲ្យគេមានសេចក្តីសង្ឃឹម និងយ៉ាងតិចឲ្យគេស្លាប់នៅក្នុងតម្លៃថ្លៃថ្នូរនៅក្នុងជីវិតរបស់គេ ទោះបីអត់មានគ្រួសារ ទោះបីអត់មានគ្រូពេទ្យ ប៉ុន្តែយ៉ាងតិចឲ្យគេស្លាប់នៅក្នុងតម្លៃថ្លៃថ្នូរ។ សម្រាប់ លូវីស និង ហ្សេលី នៅពេលគេជួបគ្នាគេរៀបការ នៅពេលគេរៀបការហើយគេមានជីវិតថ្មី ដោយយល់ថាព្រះជាម្ចាស់ចង់ឲ្យមានកូនច្រើន ដូច្នេះគេមានកូនច្រើនរហូតដល់៩នាក់។ ដើម្បីឲ្យកូនគេស្គាល់ផ្លូវនៃស្ថានបរមសុខ និងស្គាល់អំណរសប្បាយរួមជាមួយព្រះជាម្ចាស់ នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ។

នេះជាជំហានដំបូង រស់នៅក្នុងជីវិតធម្មតាប៉ុន្តែសូមបើកភ្នែក ថ្ងៃណាមួយព្រះជាម្ចាស់មានសញ្ញាមួយដើម្បីជួបយើងណែនាំឲ្យយើងភ្ញាក់ ណែនាំឲ្យយើងមានជីវិតថ្មីនៅក្នុងគម្រោងការណ៍របស់ព្រះជាម្ចាស់។ សូមចាប់អារម្មណ៍ គេមានជីវិតថ្មីប៉ុន្តែគេរស់នៅក្នុងជីវិតថ្មីហ្នឹងបានដោយសារ គេភ្ជាប់ជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ គេយល់ថា ប្រភពនៃជីវិតថ្មីរបស់គេគឺសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នេះជាមូលហេតុនៅពេលលោកសិលា ដើរជាមួយព្រះយេស៊ូនិងក្រុមគ្រីស្តទូតទាំងអស់ ព្រះយេស៊ូបានសួរថា "**ខ្ញុំជានរណា?**" ក្រុមគ្រីស្តទូតគេអត់ដឹងឆ្លើយអ្វីប៉ុន្តែលោកសិលាឆ្លើយបាន "**លោកជាព្រះបុត្រារបស់ព្រះជាម្ចាស់ ជាព្រះបុត្រាជាទីស្រឡាញ់របស់ព្រះជាម្ចាស់**"។ ពេលព្រះយេស៊ូ សួរក្រុមគ្រីស្តទូតជាលោកសិលាជាអ្នកឆ្លើយមុនគេបង្អស់ ដោយសារលោកសិលាបានយល់ចិត្តរបស់ព្រះយេស៊ូ ចូលនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូ ពីមួយថ្ងៃទៅមួយថ្ងៃយ៉ាងភ្ជាប់មែនទែន។

អ្នកម្តាយ តេរេសា គាត់មានកម្លាំងដើម្បីបម្រើអ្នកជម្ងឺដែលកំពុងស្លាប់ អ្នកជម្ងឺដែលពោរពេញដោយរបួសដោយសារគាត់អធិដ្ឋាន "**អធិដ្ឋានណែនាំឲ្យយើងមានជំនឿ ជំនឿណែនាំឲ្យយើងមានសេចក្តីស្រឡាញ់ សេចក្តីស្រឡាញ់ណែនាំឲ្យយើងជាអ្នកបម្រើ អ្នកបម្រើណែនាំឲ្យយើងបង្កើតសុខសន្តិភាព**" នេះជាពាក្យអធិដ្ឋានរបស់អ្នកម្តាយ តេរេសា។ គាត់យល់ថា អ្វីៗទាំងអស់ចេញនៅក្នុងការអធិដ្ឋាន នៅពេលគាត់ភ្ជាប់ជាមួយព្រះកាយព្រះគ្រីស្តនៅក្នុងភាពស្ងៀមស្ងាត់ នៅពេលគាត់ជាប់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិត គាត់រកឃើញកម្លាំងដើម្បីបំពេញ

តួនាទីថ្មីដែលគាត់បានទទួល បម្រើអ្នកក្រីក្រនិងលើកទឹកចិត្តអ្នកជម្ងឺឲ្យគេរស់នៅដល់ថ្ងៃចុងក្រោយ នៅក្នុងតម្លៃថ្លៃថ្នូរ។

លូវីស និង ហ្សឺលី កូនស្រីរបស់គាត់ឈ្មោះ ហ្សឺលីន ធ្លាប់និយាយថា "**ផ្ទះរបស់យើងបីដូចជាយើងអធិដ្ឋាន២៤ម៉ោងលើ២៤ម៉ោង**" គេមិនអធិដ្ឋាន២៤ម៉ោងលើ២៤ម៉ោងទេ ប៉ុន្តែគេភ្ជាប់ជាមួយព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ជាសមាជិកនៅក្នុងក្រុមគ្រួសារគេ។ លូវីស គាត់ចូលចិត្តយកពេលដើម្បីអធិដ្ឋានស្ងៀមស្ងាត់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីរកឃើញកម្លាំង ដើម្បីណែនាំគ្រួសារឲ្យចេះស្រឡាញ់ទៅវិញទៅមក។

នៅពេលយើងបានស្តាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ នៅពេលយើងភ្ជាប់ជាមួយសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដល់ពេលវេលាដើម្បីអនុវត្តន៍សេចក្តីស្រឡាញ់ហ្នឹងកុំឲ្យសេចក្តីស្រឡាញ់ទៅជាទស្សនៈមួយរវាងខ្ញុំនិងព្រះជាម្ចាស់ ព្រះជាម្ចាស់និងខ្ញុំ។ ប៉ុន្តែ យើងអនុវត្តន៍នៅក្នុងជីវិត ដូចលោកសិលាបានដើរតាមព្រះយេស៊ូពិតមែន ប៉ុន្តែលោកសិលាបានទទួលព្រះសហគមន៍ បានដឹកនាំព្រះសហគមន៍ជាសម្តេចប៉ាបដំបូងដែលព្រះយេស៊ូប្រគល់តួនាទីឲ្យគាត់ដឹកនាំព្រះសហគមន៍។ គាត់ចេញពីទីក្រុងយេរ៉ូសាឡឹមទៅដល់ទីក្រុងរ៉ូម ដើម្បីប្រកាសដំណឹងល្អរហូតដល់គាត់ទទួលមរណៈភាព។ អ្នកម្តាយ តេរេសា ពេលអធិដ្ឋានហើយគាត់នៅបន្តអធិដ្ឋានទៀតគាត់ដឹងថាអធិដ្ឋាន១ម៉ោង ២ម៉ោង ៣ម៉ោងបាន ក្រោយមកគាត់ទៅបម្រើជាក់ស្តែងមិនមែនអង្គុយលើកៅអីបញ្ជាឲ្យបងស្រីផ្សេងធ្វើនេះធ្វើនោះ ប៉ុន្តែអ្នកម្តាយ តេរេសា គាត់ទៅលាងរបួស ដើម្បីលើកទឹកចិត្ត ដើម្បីធ្វើដំណើរជាមួយអ្នកក្រីក្រយ៉ាងពិតប្រាកដមែន។ លូវីស និង ហ្សឺលី រៀងរាល់ថ្ងៃចន្ទគេបើកទ្វារផ្ទះ ដើម្បីស្វាគមន៍អ្នកក្រីក្រនិងគេណែនាំឲ្យព្រះសហគមន៍របស់គេមានជីវិត ដោយសារគេជាគ្រីស្តបរិស័ទយ៉ាងសកម្មមែនទែន និងណែនាំឲ្យក្រុមគ្រួសារនេះពោរពេញដោយសេចក្តីស្រឡាញ់និងសេចក្តីសង្ឃឹម ដោយណែនាំឲ្យគ្រួសារគេមានភាពកក់ក្តៅមានជីវិតដែលមកពីព្រះជាម្ចាស់មែន ប៉ុន្តែកក់ក្តៅរវាងបងប្អូននិងបងប្អូន រវាងកូននិងម្តាយ រវាងប្តីនិងប្រពន្ធ នេះគេអនុវត្តន៍យ៉ាងជាកស្តែងអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

ខ្ញុំជឿថាបងប្អូនឯទៀតៗ ដែលមើលសិលាគេមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលមើលអ្នកម្តាយ តេរេសា គេមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ នៅពេលមើលក្រុមគ្រួសាររបស់ លូវីស និង ហ្សឺលី គេមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់យ៉ាងជាក់ស្តែង។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ យើងនិយាយយ៉ាងស្រួលណាស់ ប៉ុន្តែឲ្យអនុវត្តន៍នៅក្នុងជីវិតរបស់យើង។ សូមលោកបូជាចារ្យទាំងអស់ ជួយយុវជនយើងឲ្យស្គាល់សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ សក្ខីភាពរបស់លោកឪពុកសំខាន់ណាស់ សក្ខីភាពរបស់បងស្រី

សំខាន់ណាស់ ដើម្បីឲ្យយុវជនយុវនារីអាចមើលឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់ ជាពិសេសឲ្យម្នាក់ៗមើលឃើញសញ្ញាមួយនៅក្នុងជីវិតផ្ទាល់ **តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីសម្រាប់ខ្ញុំ?** ឲ្យយើងបើកភ្នែកធំៗអត់មានអ្វីអស្ចារ្យ ដូចព្រះនាងម៉ារីពេលកំពុងបោសសម្រាមមានទេវទូតកាព្រីអែលចុះមកពីខាងលើ ឲ្យធ្វើជាមាតារបស់ព្រះយេស៊ូ ដូច្នេះត្រៀមខ្លួនជានិច្ច។ គម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់ជីវិតខ្ញុំ គឺឲ្យយើងអធិដ្ឋាន ដោយបើកភ្នែក បើកត្រចៀក ដោយបើកបេះដូង ដើម្បីរស់នៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដើម្បីរស់នៅក្នុងផ្លូវដែលព្រះជាម្ចាស់បង្ហាញឲ្យយើងយ៉ាងជាក់ស្ដែង ដោយទុកសំណួរនេះនៅពេលយើងធ្វើដំណើរដល់ព្រះសហគមន៍របស់យើងវិញ **តើព្រះជាម្ចាស់មានគម្រោងការណ៍អ្វីខ្លះសម្រាប់ជីវិតខ្ញុំជាយុវជនជាយុវនារីកាតូលិកនៅក្នុងព្រះសហគមន៍កាតូលិកកម្ពុជា?** អាម៉ែន៕